បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...១៣...ខែ...០១...ឆ្នាំ 20១៧
ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌលេខ ០៤ "ជ១"
ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ ១២០៤
ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤
សំណុំរឿងស៊ើបសួរលេខ ១៤០៥
ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤
សំណុំរឿងជំនុំជម្រះលេខ ១៥៣៤
ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

[redacted]

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ០៨ : ៣០ នាទី នៅសាលសវនាការទី២ ជាន់ទី១ ដោយមានសមាសភាព៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២០៤ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ ដែលមាន៖ ជនជាប់ចោទឈ្មោះ [redacted] ជ័យ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] លាង "ស" ម្តាយឈ្មោះ [redacted] រីម "រ" ប្រពន្ធឈ្មោះ [redacted] ចាន់នី "រ" មានកូន០២នាក់ ជាទីតិជន ទោសពីមុនគ្មាន ។

<u>ជាប់ចោទពីបទ</u>៖ ផ្តល់សក្ខីកម្មក្លែងក្លាយ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក [redacted] លោក [redacted] លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

<u>ដើមបណ្តឹងរដ្ឋប្បវេណី</u> [redacted] ណាត ភេទប្រុស អាយុ៤២ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៥E, ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ ឈ្មោះ [redacted] ណាត បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] រីម និង [redacted] ជ័យ ពីបទរំលោភលំនៅដ្ឋាន ហើយប្តឹងឈ្មោះ [redacted] សុឃឹម ពីបទកំហែងយក និងបទ បំពានលើកម្មសិទ្ធអ្នកដទៃ ប្រព្រឹត្តកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ។ យោងតាមលិខិតបញ្ជាក់ជាផ្លូវការចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់ឯកឧត្តមអគ្គស្នងការរងនគរបាលជាតិ និងជាស្នងការរាជធានីភ្នំពេញ បានបញ្ជាក់ថា លោក [redacted] ឃឹម និងលោក [redacted] ជ័យ ពុំបាននៅបរិវេនទីកន្លែងកើតហេតុកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ព្រោះពួកគាត់ជាប់រវល់ប្រចាំការនៅមុខវិមានសន្តិភាព ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ ចាប់ពីម៉ោង០៦ព្រឹក ដល់ម៉ោង ២២យប់ ក្នុងកិច្ចប្រជុំអាស៊ានទី២១ ។ ប៉ុន្តែក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣១៤០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ឈ្មោះ [redacted] ជ័យ ជាសាក្សី បានចូលឆ្លើយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅចំពោះមុខអយ្យការថា នៅថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ២០១២ វេលាម៉ោងជិតពីរថ្ងៃត្រង់ ម្តាយមីងឈ្មោះ



Scanned with CamScanner

[redacted] រឹម បានទូរស័ព្ទប្រាប់ថាឈ្មោះ [redacted] ណាត បានជេរប្រមាថគាត់ និងបានគំរាមកំហែងគាត់ដោយអាវុធ ឮសូរដូច្នោះខ្លួនបានទៅដល់ផ្ទះគាត់ដើម្បីមើលហេតុការណ៍នោះ ។ នៅពេលទៅដល់ទីនោះ ខ្លួនបានឃើញប្រធានភូមិឈ្មោះ អ៊ុំ រ៉ាវី កំពុងឈរជជែកគ្នាជាមួយឈ្មោះ [redacted] ណាត អំពីរឿងដែលឈ្មោះ [redacted] ណាត ធ្វើការជួសជុលផ្ទះដោយគ្មានច្បាប់អនុញ្ញាត ។ បន្ទាប់មកខ្លួនបានឡើងទៅលើផ្ទះឈ្មោះ [redacted] ណាត ក្នុងគោលបំណងទៅមើលហេតុការណ៍ តែនៅពេលខ្លួនមិនទាន់ឡើងដល់លើផ្ទះផងឈ្មោះ [redacted] ណាត បានស្រែកពីលើផ្ទះថា "អាណាហ៊ានចូលក្នុងផ្ទះអញ ផ្តាច់តឹងឥឡូវ" ពេលនោះខ្លួនឃើញនៅក្នុងដៃរបស់ឈ្មោះ [redacted] ណាត មានកាន់កាំភ្លើងខ្លី តែខ្លួនមិនដឹងម៉ាកអ្វីទេ ព្រោះគាត់បានកាន់សំពៀងពេញផ្ទះ ឃើញដូចនោះខ្លួនក៏ចុះក្រោមវិញ ។ ដោយឈ្មោះ ឃុត ជ័យ បានបញ្ជាក់បន្ថែមថានៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ នោះខ្លួនពិតជាបានឃើញឈ្មោះ [redacted] ណាត មានកាំភ្លើងខ្លីពិតមែន ។ តាមរយៈចម្លើយនេះធ្វើឲ្យតំណាងអយ្យការបានចោទប្រកាន់ឈ្មោះ [redacted] ណាត ពីបទគំរាមកំហែងទៅតុលាការ ។ យោងទៅលើចម្លើយខាងលើរបស់ឈ្មោះ [redacted] ជ័យ គឺពិតជាបានឆ្លើយបំពានលើសេចក្តីបញ្ជាក់ជាផ្លូវការរបស់ឯកឧត្តមអគ្គស្នងការរងនគរបាលជាតិនិងជាស្នងការរាជធានីភ្នំពេញ ហើយក៏ជាករណីផ្តល់សក្ខីកម្មក្លែងក្លាយ បកតំណាងអយ្យការកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ប្រាកដមែន ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៣៨៨ អ.យ.ភ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧៤ អ.យ.ភ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៦២៥ "ណ" ដ.ជ.រ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## <u>នារពលសទនាភារ</u>

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជ័យ ដែលបានឆ្លើយថា៖ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ មេរបស់ខ្លួនបានប្រើខ្លួនឲ្យរករ៉ូឡូដោតភ្លើង ខ្លួនក៏មកយករ៉ូឡូភ្លើងនៅផ្ទះមេ ពេលខ្លួនទៅដល់ផ្ទះនោះ ខ្លួនបានឃើញប្រពន្ធរបស់មេ កំពុងជជែកគ្នាជាមួយឈ្មោះ [redacted] ណាត ដោយឮសូរឈ្មោះ [redacted] ណាត ស្រែកថា "អាណាហ៊ានចូលមកប្រកាច់គ្រឿងឥឡូវ" ឃើញដៃម្ខាងមានកាន់កាំភ្លើង រួចខ្លួនបានយករ៉ូឡូភ្លើងចេញ។ ពេលប្រធានាធិបតីមកប្រជុំអាស៊ានទៅប្រទេសយើង នោះខ្លួនពិតជាមានបេសកកម្មប្រចាំការនៅមុខវិមានសន្តិភាពមែន តែខ្លួនមិនចាំថ្ងៃខែទេ ចាំតែក្នុងឆ្នាំ២០១២។

-ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត ដែលបានឆ្លើយថា៖ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ ខ្លួនដាក់ពាក្យបណ្តឹងឈ្មោះ [redacted] រឹម និងឈ្មោះ [redacted] ជ័យ ពីបទរំលោភបើលំនៅដ្ឋាន ប្រព្រឹត្តកាលពីឆ្នាំ២០១២ ពេលនោះឈ្មោះ [redacted] ជ័យ បានឆ្លើយនៅមុខតំណាងអយ្យការថា នៅថ្ងៃនោះខ្លួនពុំបានទៅកន្លែងកើតហេតុដូចការចោទប្រកាន់ទេ ដោយមានលិខិតបញ្ជាក់ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។ យោងតាមចម្លើយរបស់ឈ្មោះ [redacted] ជ័យ និងលិខិតបញ្ជាក់ខាងលើនេះ តំណាងអយ្យការបានចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៥៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ នោះទៅ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ឈ្មោះ [redacted] រឹម បានប្តឹងខ្លួននៅនាយកដ្ឋានព្រហ្មទណ្ឌពីបទ គំរាមកំហែងដោយអាវុធ ហើយឈ្មោះ [redacted] ជ័យ បានផ្តល់ចម្លើយនៅអយ្យការក្នុងនាមជាសាក្សីឲ្យឈ្មោះ [redacted] រឹម ថានៅថ្ងៃកើតហេតុខ្លួនពិតជាបានឃើញឈ្មោះ ឃឿង ណាត យកកាំភ្លើងគំរាមកំហែងឈ្មោះ សួស រឹម ប្រាកដមែន។ ដោយហេតុថាចម្លើយរបស់ឈ្មោះ [redacted] ជ័យ និងលិខិតបញ្ជាក់របស់ឈ្មោះ [redacted] ជ័យ ធ្វើឲ្យខ្លួនជាជនរងគ្រោះរហូតដល់មានបីសំណុំរឿង។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ហេតុនេះ តំណាងអយ្យការប្តឹងសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧៤ អ.យ.ឆ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ ទុកដដែល និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដោយសារតែមានបញ្ហាទំនាស់គ្នារវាងលោក [redacted] យឹម ជាមួយលោក [redacted] ណាត បានធ្វើឲ្យលោក [redacted] ណាត ដែលធ្វើអ្វីលោក [redacted] យឹម និងប្រពន្ធមិនបានទើបដាក់មកប្តឹងទម្លាក់កំហុសមួលបង្កាច់ដាក់លោក [redacted] ជ័យ ដែលគ្មានកំហុសទៅវិញ។ ក្រោយពីប្តឹងផ្តល់គ្នាមួយរយៈមក ទើបភាគីទាំងអស់ធ្វើការសម្រុះសម្រួលគ្នា ពីព្រោះភាគីទាំងអស់សុទ្ធតែជាសមត្ថកិច្ចនគរបាលដូចគ្នា និងម្យ៉ាងទៀតកុំឲ្យមានការគុំគួនគ្នាបន្តទៀត ទើបភាគីទាំងអស់បានចុះកិច្ចព្រមព្រៀងបញ្ចប់វិវាទនិងគ្នា ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ និងយល់ព្រមដកពាក្យបណ្តឹងរៀងៗខ្លួន ឈប់ប្តឹងផ្តល់គ្នាបន្តទៅទៀត ព្រមទាំងសន្យារាប់អានគ្នាដូចបងប្អូន ចាប់ពីពេលចុះកិច្ចព្រមព្រៀងបញ្ចប់វិវាទតទៅ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំតុលាការសម្រេចឱ្យ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៦២៥ "ឍរ" ដ.ជ.រ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនឈ្មោះ [redacted] ជ័យ ទៅជំនុំជម្រះពីបទ៖ ផ្តល់សក្ខីកម្មក្លែងក្លាយ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ ។

២-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជ័យ ដែលបានឆ្លើយថា៖ មេរបស់ខ្លួនបានប្រើខ្លួនឲ្យរករ៉ូឡូដោតភ្លើង ខ្លួនក៏មកយករ៉ូឡូភ្លើងនៅផ្ទះគាត់ ពេលខ្លួនទៅដល់ផ្ទះនោះ ខ្លួនបានឃើញប្រពន្ធរបស់មេ កំពុងជជែកគ្នាជាមួយឈ្មោះ [redacted] ណាត ដោយឮសួរឈ្មោះ [redacted] ណាត ស្រែកថា "អាណាហ៊ានចូលមកប្រកាច់គ្រឿងឥឡូវ" ឃើញដៃគាត់ម្ខាងមានកាន់កាំភ្លើង រួចខ្លួនបានយករ៉ូឡូភ្លើងចេញ។

៣-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត ដែលបានឆ្លើយថា៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ឈ្មោះ [redacted] រឹម បានប្តឹងខ្លួននៅនាយកដ្ឋានព្រហ្មទណ្ឌពីបទ គំរាមកំហែងដោយអាវុធ ហើយឈ្មោះ [redacted] ជ័យ បានផ្តល់ចម្លើយនៅអយ្យការក្នុងនាមជាសាក្សីឲ្យឈ្មោះ [redacted] រឹម ថានៅថ្ងៃកើតហេតុខ្លួនពិតជាបានឃើញឈ្មោះ [redacted] ណាត យកកាំភ្លើងគំរាមកំហែងឈ្មោះ [redacted] រឹម ប្រាកដមែន។ ដោយហេតុថាចម្លើយរបស់ឈ្មោះ [redacted] ជ័យ និងលិខិតបញ្ជាក់របស់ឈ្មោះ [redacted] ជ័យ ធ្វើឲ្យខ្លួនជាជនរងគ្រោះរហូតដល់មានបីសំណុំរឿង។



Scanned with CamScanner

៤-តាមអំណានចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងផ្សេងៗដែលមានឃើញថា មានភាពស៊ីចង្វាក់គ្នាដែលអាចបញ្ជាក់បានថា៖ ជនជាប់ចោទឈ្មោះ [redacted] ជ័យ ពិតជាបានធ្វើសកម្មភាពដូចការចោទប្រកាន់ប្រាកដមែន ។

៥-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ជ័យ ពីបទ ផ្តល់សក្ខីកម្មក្លែងក្លាយ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ ។

៦-ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃ ហើយបំពានទៅលើនីត្យានុកូលភាពសង្គមដែលច្បាប់បានការពារ ។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ជ័យ ពីបទ ផ្តល់សក្ខីកម្មក្លែងក្លាយ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ ។

៨-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត បានដកពាក្យបណ្តឹងតាមលិខិតសុំដកពាក្យបណ្តឹងកាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩។ គប្បីតុលាការមិនពិចារណាអំពីសំណងទៀតទេ។

## ហេតុដូច្នេះសម្រេច

ផ្តន្ទាទោសលើឈ្មោះ [redacted] ជ័យ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរទាំងមូលស្តីពីការព្យួរទោសធម្មតា។

ពីបទ៖ ផ្តល់សក្ខីកម្មក្លែងក្លាយ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃសុក្រ ៩កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]